ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រលអស
SSCA

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

លេខ: ០១៧៥ រ.ល.អ.ស

# សេចក្តីជូនដំណឹង
# ស្តីពីការជ្រើសរើសមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខណ្ឌ
# នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ឆ្នាំ២០២១

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សូមជម្រាបជូនដំណឹងដល់សាធារណៈជនមេត្តាជ្រាបថា៖ សម្រាប់ឆ្នាំ២០២១នេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលត្រូវការជ្រើសរើសមន្ត្រីរាជការបច្ចេកទេសចំនួន ១២នាក់ ដើម្បីចូលបម្រើការងារនៅ៖ នាយកដ្ឋានស្តង់ដារនិងសុវត្ថិភាពអាកាសយានដ្ឋាន នាយកដ្ឋានស្តង់ដារ និងសុវត្ថិភាពនាំផ្លូវអាកាស នាយកដ្ឋានលទ្ធភាពហោះហើរ និងនាយកដ្ឋានសន្តិសុខអាកាសចរស៊ីវិល នៃក្របខណ្ឌរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលដូចខាងក្រោម៖

**<u>លក្ខណៈសម្បត្តិបេក្ខជន</u>**

**១-សម្រាប់មុខតំណែងមន្ត្រីព័ត៌មានវិទ្យាចំនួន ០៣នាក់៖**

- បេក្ខជនទាំង ០២ ភេទ មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៤៥ឆ្នាំ មានសញ្ជាតិ ខ្មែរ
- កម្រិតវប្បធម៌ ៖ បរិញ្ញាបត្រ
- កម្រិតជំនាញ ៖ ផ្នែកព័ត៌មានវិទ្យា
- បទពិសោធន៍ ៖ ធ្លាប់បម្រើការងារលើជំនាញខាងលើយ៉ាងតិច ១ឆ្នាំ
- ភាសាអង់គ្លេស ៖ អាចសរសេរ និងនិយាយបានកម្រិតមធ្យម

**២- សម្រាប់មុខតំណែងរៀបចំបទប្បញ្ញត្តិសេវាកម្មនាំផ្លូវអាកាសចំនួន ០២នាក់៖**

- បេក្ខជនទាំង ០២ ភេទ មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៤៥ឆ្នាំ មានសញ្ជាតិ ខ្មែរ
- កម្រិតវប្បធម៌ ៖ បរិញ្ញាបត្រ
- កម្រិតជំនាញ ៖ ផ្នែកគ្រប់គ្រងសេវាកម្មចរាចរផ្លូវអាកាស ឬភាសាអង់គ្លេស
- បទពិសោធន៍ ៖ ធ្លាប់បម្រើការងារលើជំនាញខាងលើយ៉ាងតិច ១ឆ្នាំ
- ភាសាអង់គ្លេស ៖ អាចសរសេរ និងនិយាយបានកម្រិតខ្ពស់

**៣- សម្រាប់មុខតំណែងរៀបចំបទប្បញ្ញត្តិបរិស្ថានអាកាសយានដ្ឋានចំនួន ០២នាក់៖**

- បេក្ខជនទាំង ០២ ភេទ មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៤៥ឆ្នាំ មានសញ្ជាតិ ខ្មែរ
- កម្រិតវប្បធម៌ ៖ បរិញ្ញាបត្រ
- កម្រិតជំនាញ ៖ ផ្នែកគ្រប់គ្រងបរិស្ថាន ឬភាសាអង់គ្លេស
- បទពិសោធន៍ ៖ ធ្លាប់បម្រើការងារលើជំនាញខាងលើយ៉ាងតិច ១ឆ្នាំ
- ភាសាអង់គ្លេស ៖ អាចសរសេរ និងនិយាយបានកម្រិតខ្ពស់

**៤- សម្រាប់មុខតំណែងរៀបចំបទប្បញ្ញត្តិសន្តិសុខអាកាសចរស៊ីវិលចំនួន ០២នាក់៖**

- បេក្ខជនទាំង ០២ ភេទ មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៤៥ឆ្នាំ មានសញ្ជាតិ ខ្មែរ

លេខ ៤៤ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មហាវិថីសហព័ន្ធរុស្ស៊ី
ភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ : ៨៥៥-២៣ ៨៩០ ១៥៨ / ទូរសារ : ៨៥៥-២៣ ៨៩០ ១០២/៨៥៥-២៣ ៨៩០ ១០៨
អ៊ីម៉ែល : ssca-int@ssca.gov.kh

- កម្រិតវប្បធម៌ ៖ បរិញ្ញាបត្រ
- កម្រិតជំនាញ ៖ ផ្នែកច្បាប់ ឬភាសាអង់គ្លេស
- បទពិសោធន៍ ៖ ធ្លាប់បម្រើការងារលើជំនាញខាងលើយ៉ាងតិច ១ឆ្នាំ
- ភាសាអង់គ្លេស ៖ អាចសរសេរ និងនិយាយបានកម្រិតខ្ពស់

**៥- សម្រាប់មុខតំណែងរៀបចំបទប្បញ្ញត្តិលទ្ធភាពហោះហើរចំនួន ០២នាក់៖**

- បេក្ខជនទាំង ០២ ភេទ មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៤៥ឆ្នាំ មានសញ្ជាតិ ខ្មែរ
- កម្រិតវប្បធម៌ ៖ បរិញ្ញាបត្រ
- កម្រិតជំនាញ ៖ ផ្នែកវិស្វកម្មតំហែទាំអាកាសយាន ឬភាសាអង់គ្លេស
- បទពិសោធន៍ ៖ ធ្លាប់បម្រើការងារលើជំនាញខាងលើយ៉ាងតិច ១ឆ្នាំ
- ភាសាអង់គ្លេស ៖ អាចសរសេរ និងនិយាយបានកម្រិតខ្ពស់

**៦- សម្រាប់មុខតំណែងរៀបចំបទប្បញ្ញត្តិអាជ្ញាបណ្ណបុគ្គលិកចំនួន ០១នាក់៖**

- បេក្ខជនទាំង ០២ ភេទ មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៤៥ឆ្នាំ មានសញ្ជាតិ ខ្មែរ
- កម្រិតវប្បធម៌ ៖ បរិញ្ញាបត្រ
- កម្រិតជំនាញ ៖ ផ្នែកវិស្វកម្មតំហែទាំអាកាសយាន ឬភាសាអង់គ្លេស
- បទពិសោធន៍ ៖ ធ្លាប់បម្រើការងារលើជំនាញខាងលើយ៉ាងតិច ១ឆ្នាំ
- ភាសាអង់គ្លេស ៖ អាចសរសេរ និងនិយាយបានកម្រិតខ្ពស់

*ពាក្យសុំសម្ភាសដើម្បីចូលបម្រើការងារនៅ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បេក្ខជនត្រូវទាញយកដោយផ្ទាល់ពីក្នុងគេហទំព័ររបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលគឺ៖ http://www.civilaviation.gov.kh ត្រង់ចំណុចព័ត៌មាន (News) ដោយចុចលើពាក្យសុំសម្ភាសចូលបម្រើការងារនៅរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

**<u>បេក្ខជនត្រូវមកដាក់ពាក្យនិងភ្ជាប់មកជាមួយនូវ៖</u>**

| | |
|---|---|
| - ពាក្យសុំចូលសម្ភាស | ចំនួន០១ច្បាប់ |
| - ជីវប្រវត្តិសង្ខេបមានបិទរូបថត ៤x៦ | ចំនួន០១ច្បាប់ |
| - សលាកបត្រឯកត្តជន | ចំនួន០១ច្បាប់ |
| - បង្កាន់ដៃទទួលពាក្យសុំសិទ្ធិសម្ភាស | ចំនួន០១ច្បាប់ |
| - កិច្ចសន្យាការងារ | ចំនួន០១ច្បាប់ |
| - សេចក្តីចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ | ចំនួន០១ច្បាប់ |
| - សេចក្តីចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ | ចំនួន០១ច្បាប់ |
| - សេចក្តីចម្លងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត | ចំនួន០១ច្បាប់ |
| - លិខិតបញ្ជាក់សុខភាព (ក្រោយពេលសម្ភាសជាប់) | ចំនួន០១ច្បាប់ |
| - លិខិតថ្កោលទោស (ក្រោយពេលសម្ភាសជាប់) | ចំនួន០១ច្បាប់ |

**<u>បញ្ជាក់</u>**៖ រាល់លិខិតពាក់ព័ន្ធដែលតម្រូវត្រូវមានការបញ្ជាក់ជាផ្លូវការត្រឹមត្រូវ។
*ចំពោះសញ្ញាបត្រដែលបានបញ្ចប់ការសិក្សាពីបរទេសត្រូវយកទៅបញ្ជាក់ជាភាសាជាតិដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។ ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធ នៃលក្ខន្តិកៈមន្ត្រីរាជការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បេក្ខជនដែលជាប់មានកាតព្វកិច្ចបំពេញបន្ថែម។

**<u>ផលប្រយោជន៍</u>**

បេក្ខជនដែលត្រូវបានជ្រើសរើសដោយគណៈកម្មការជ្រើសរើសបុគ្គលិកបច្ចេកទេសរបស់ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលនឹងទទួលបានផលប្រយោជន៍ដូចខាងក្រោម៖

- ជាបុគ្គលិកបច្ចេកទេសពេញសិទ្ធិរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ទទួលបានបៀវត្សទៅតាមប្រភេទកាំប្រាក់ជំនាញបច្ចេកទេស
- ទទួលបានប្រាក់រង្វាន់លើកទឹកចិត្តប្រចាំខែតាមការកំណត់របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ទទួលបានការបណ្តុះបណ្តាលទៅតាមកម្មវិធីបណ្តុះបណ្តាលរបស់បុគ្គលិកបច្ចេកទេស
- ទទួលបានការតម្លើងមុខតំណែងទៅតាមសមិទ្ធិផលការងាររបស់បុគ្គលិកបច្ចេកទេស
- ទទួលបានការចូលរួមកិច្ចប្រជុំ ឬសិក្ខាសាលានៅក្រៅប្រទេស
- ទទួលបានប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេសតាមអនុក្រឹត្យលេខ២១៦ អនក្រ.បក ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ទទួលបានឯកសណ្ឋានចំនួន ២សម្រាប់ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលប្រចាំឆ្នាំ
- ទទួលបានការឈប់សម្រាកទៅតាមអនុក្រឹត្យស្តីពីប្រតិទិនឈប់សម្រាករបស់មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និយោជិត កម្មករ ប្រចាំឆ្នាំ
- ទទួលបានរបបឈប់សម្រាកបន្ថែម ១៥ថ្ងៃក្នុង១ឆ្នាំ តាមអនុក្រឹត្យស្តីពីរបបឈប់សម្រាកប្រចាំឆ្នាំរបស់មន្ត្រីរាជការ
- ទទួលបានការអនុវត្តន៍ជំនាញនៅតាមបណ្តាក្រុមហ៊ុនអាកាសចរ ដើម្បីរក្សាសុពលភាពអាជ្ញាប័ណ្ណនិងពង្រឹងជំនាញវិជ្ជាជីវៈអាកាសចរស៊ីវិល
- ទទួលបានប្រាក់សោធននិវត្តន៍ពេលចូលនិវត្តន៍ និង
- ទទួលបានផលប្រយោជន៍ដទៃទៀតដែលត្រូវបានកំណត់ដោយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

**ទីកន្លែងទទួលពាក្យ៖**

នៅនាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រងធនធានមនុស្ស នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលមានអាសយដ្ឋានលេខ៖ ៤៤ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ទូរស័ព្ទលេខ៖ ០២៣ ៨៩០១៩៨

ទូរសារលេខ៖ ០២៣ ៨៩០១០២

គេហទំព័រ៖ www.civilaviation.gov.kh

ការទទួលពាក្យនឹងចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ នៅរៀងរាល់ថ្ងៃធ្វើការ៖ ចាប់ពីម៉ោង ៨:០០ព្រឹក រហូតដល់ម៉ោង ១៦:០០ល្ងាច។

**ព័ត៌មានផ្សេងៗ៖**

សូមអញ្ជើញទាក់ទងនៅនាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រងធនធានមនុស្ស នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ឬតាមរយៈលេខទូរស័ព្ទ៖០២៣ ៨៩០១៩៨។

ថ្ងៃចន្ទ ៤រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ម៉ៅ ហាចណ្ណារ៉ាល់**